ទំនុកដំកើង១៥០:១-៦

ទំព័រ ១៥០

ជាវចនា *បទថ្វាយបង្គំដោយប្រើឧបករណ៍តន្ត្រីគ្រប់ប្រភេទ យ៉ាងច្រើនក្រៀបក្រា*

**[1]ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះ នៅក្នុងទី
បរិសុទ្ធរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ នៅចន្លោះអាកាស ជាទី
សំដែងព្រះចេស្តាទ្រង់ [2]ចូរសរសើរដល់ទ្រង់ ដោយព្រោះការ
ឥទ្ធិឫទ្ធិរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ ឱ្យសមនឹងសណ្ឋានដ៏ធំ
ប្រសើររបស់ទ្រង់ [3]ចូរសរសើរទ្រង់ដោយស្នូរត្រែ ចូរសរសើរដល់
ទ្រង់ដោយដេញពិណនឹងចាប់ស៊ីង [4]ចូរសរសើរទ្រង់ដោយវាយ
ក្រាប់ ហើយលោតកញ្ឆេង ចូរសរសើរទ្រង់ដោយប្រដាប់មាន
ខ្សែ ហើយនឹងខ្ទុយ [5]ចូរសរសើរដល់ទ្រង់ដោយវាយឈឹងឱ្យឮរងំ
ចូរសរសើរទ្រង់ដោយវាយឈឹងឮស្នូរពីរពង [6]គ្រប់ទាំងឱ្យជីវិតទាំងឡាយ
ដែលមានដង្ហើម បានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់
ព្រះយេហូវ៉ាចុះ (ទំនុកដំកើង១៥០:១-៦)។**

គម្ពីរទំនុកដំកើងជំពូក១៥០ សម្តែងពីការថ្វាយបង្គំព្រះជាម្ចាស់ជាលក្ខណៈសកលផង ជាលក្ខណៈអចិន្ត្រៃយ៍ផង។ ការថ្វាយបង្គំ ពណ៌នាក្នុងជំពូកនេះ ជាសកម្មភាពធំបង្អស់ដែលត្រូវប្រព្រឹត្តទៅជាកិច្ចការប្រចាំថ្ងៃនៅស្ថានសួគ៌។ ដោយសារនៅស្ថានសួគ៌ យើងត្រូវថ្វាយបង្គំព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ យើងចាំបាច់ត្រូវពិចារណាអោយបានច្បាស់លាស់ពីខ្លឹមសារនៃការថ្វាយបង្គំព្រះជាម្ចាស់ ដែលយើងតែងប្រព្រឹត្តពេលយើងរស់នៅលើផែនដីនេះ។ ដើម្បីអោយយល់ច្បាស់ពីខ្លឹមសារនៃការថ្វាយបង្គំព្រះ យើងត្រូវចោទសួរនូវសំណួរបីយ៉ាងធំៗគឺ មួយ តើអ្វីទៅជាការថ្វាយបង្គំ? សំណួរទីពីរ តើអ្នកណាមានសិទ្ធិថ្វាយបង្គំ? ឯសំណួរទីបីគឺ ហេតុអ្វីបានជាយើងចាំបាច់ត្រូវថ្វាយបង្គំព្រះជាម្ចាស់? សូមយើងដោះស្រាយសំណួរទាំងបីយ៉ាងនេះ ដូចខាងក្រោម។

តើអ្វីទៅជាការថ្វាយបង្គំ?

ដើម្បីឆ្លើយនឹងសំណួរនេះ ទីមួយយើងត្រូវស្គាល់អោយច្បាស់ពីអង្គដែលយើងត្រូវថ្វាយបង្គំទ្រង់។ តើអង្គណាដែលស័ក្តិសមនឹងទទួលការថ្វាយបង្គំពីសំណាក់មនុស្សជាតិ រួមទាំងមាបនភាវៈនិងមាបនវត្ថុនានា? មនុស្សលោកតែងលើកមនុស្សឬវត្ថុអ្វីមួយធ្វើជាទីសក្ការៈ។ ការនោះកើតឡើងមកពីហេតុតែគេមិនដឹង។ ចុះចំពោះអ្នកដែលបានទទួលសេចក្តីព្រោសលោះ តើគេត្រូវថ្វាយបង្គំអង្គណា? គម្ពីរទំនុកដំកើង១៥០:១ សម្តែងថា "ចូរសរសើរដល់ព្រះយេហូវ៉ា..."។ អ្នកដែលបានទទួលការព្រោសលោះពី

ព្រះអម្ចាស់យេស៊ូវ អង្គដែលគេត្រូវថ្វាយបង្គំគឺព្រះយេហូវ៉ា។

ជំពូក១៥០សង្កត់ន័យយ៉ាងធ្ងន់លើសេចក្តីពិតពីរយ៉ាង ម្យ៉ាងព្រះយេហូវ៉ាទ្រង់ជាអង្គនិម្មាបនិក ហើយម្យ៉ាងទៀតព្រះយេហូវ៉ាទ្រង់ជាព្រះដែលផ្តល់នូវសេចក្តីប្រោសលោះដល់មនុស្សមានបាប។ ព្រះយេហូវ៉ាទ្រង់ជាព្រះដែលបានបង្កើតផ្ទៃមេឃ ផែនដី និងលោកសន្និវាសដែលយើងកំពុងរស់នៅ។ ពន្លឺថ្ងៃដែលលោកអ្នកកំពុងប្រើប្រាស់សព្វថ្ងៃ ជាស្នាព្រះហស្តរបស់ព្រះអង្គ។ អ្វីៗដែលលោកអ្នកប៉ះពាល់ដោយវិញ្ញាណទាំងប្រាំរបស់លោកអ្នក ជាស្នាព្រះហស្តដែលទ្រង់បានបង្កើតមក ឥតមានអ្វីមួយក្រៅពីព្រះអង្គដែលទ្រង់មិនបានបង្កើតមកទាល់តែសោះ។ ព្រះជាម្ចាស់ទ្រង់ជាអង្គនិម្មាបនិក និងជាព្រះតែមួយអង្គគត់ដែលផ្តល់នូវសេចក្តីប្រោសលោះ។ ទ្រង់បានបង្កបង្កើតផ្ទៃមេឃនិងផែនដី ឥតមានជនណាម្នាក់ហ៊ានអួតជាមួយទ្រង់។ ខាងឯការប្រោសលោះដល់ព្រលឹងមនុស្សមានបាប ក៏គ្មានជនណាម្នាក់អាចហ៊ានអួតជាមួយនឹងព្រះអង្គដែរ។ ដោយសារព្រះអង្គបំពេញតួនាទីទាំងពីរនេះហើយ បានជាព្រះអង្គបង្គាប់ដល់មាបនភាវៈទាំងឡាយទាំងពួង ត្រូវថ្វាយបង្គំទ្រង់ ត្រូវលើកតម្កើងព្រះនាមទ្រង់ ព្រមទាំងថ្វាយដល់ទ្រង់នូវកិរិយាសរសើរគ្រប់បែបយ៉ាង។

ម្យ៉ាងវិញទៀត ព្រះគម្ពីរសម្តែងថា ព្រះយេហូវ៉ាទ្រង់ជាព្រះដែលមានព្រះហឫទ័យប្រចណ្ឌ។ ទ្រង់មានអភ័យឯកសិទ្ធិខ្ពស់បណ្តាច់អាចធ្វើការប្រចណ្ឌចំពោះមនុស្សលោក។ ព្រះអង្គបង្កើតមនុស្សលោកមកសម្រាប់អង្គទ្រង់។ ព្រះអង្គសម្តែងជំណើរនេះអោយយើងឃើញក្នុងរូបភាពប្តីប្រពន្ធស្រឡាញ់គ្នា។ ទំនាក់ទំនងរវាងប្តីនិង

ប្រពន្ធ មានតម្លៃស្មើនិងទំនាក់ទំនងរវាងពួកអ្នកជឿជាមួយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ បើប្តីពិតជាស្រឡាញ់ប្រពន្ធមែន ប្តីមិនបណ្តោយអោយប្រុសដទៃ មករួមរក្សជាមួយប្រពន្ធទេ។ សេចក្តីស្រឡាញ់របស់នាងសម្រាប់តែប្តីរបស់ខ្លួនតែម្នាក់ប៉ុណ្ណោះ។ នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ អ្នកជឿជាភរិយាថ្មោងថ្មីរបស់ព្រះគ្រីស្ទ។ ព្រះគ្រីស្ទបានលោះអ្នកជឿចេញពីអំពើបាបសម្រាប់អង្គទ្រង់។ ដូច្នេះ ព្រះអម្ចាស់យេស៊ូវគ្រីស្ទគួរទទួលពាក្យសរសើរតម្កើង ទទួលការថ្វាយបង្គំពីរាស្ត្ររបស់ទ្រង់ ដែលទ្រង់បានជ្រោសលោះដោយព្រះលោហិតរបស់ព្រះអង្គ។

នៅក្នុងទេពនិមិត្តមួយ លោកយ៉ូហានបានក្រាបថ្វាយបង្គំដល់ទេវតា។ ពេលនោះទេវតាបន្ទោសលោកថា "...កុំឱ្យធ្វើដូច្នេះឡើយ ខ្ញុំក៏ជាចាវបំរើជាមួយនឹងអ្នកដែរ ហើយជាមួយនឹងពួកហោរា ជាបងប្អូនអ្នក នឹងពួកអ្នកដែលកាន់តាមព្រះបន្ទូលក្នុងគម្ពីរនេះផង ចូរថ្វាយបង្គំដល់ព្រះវិញចុះ" (វិវរណៈ:២២:៩)។ ព្រះជាម្ចាស់មិនចង់អោយមនុស្សលោកថ្វាយបង្គំទេវតាណាមួយដែលទ្រង់បង្កើតមកទេ។ មិនតែប៉ុណ្ណោះ ព្រះអង្គមិនចង់អោយមនុស្សលោកថ្វាយបង្គំដល់នាងម៉ារា ឬមនុស្សណាម្នាក់ដែរ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យអោយមនុស្សលោកថ្វាយបង្គំដល់ទ្រង់តែមួយអង្គប៉ុណ្ណោះ។ ព្រះយេហូវ៉ាជាអង្គស័ក្តិសមនឹងទទួលការថ្វាយបង្គំ។ ខ៦ចែងថា "គួរឱ្យជីវិតទាំងឡាយដែលមានដង្ហើមបានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ"។ តើនរណាដែលយើងត្រូវថ្វាយបង្គំ? ព្រះយេហូវ៉ាជាព្រះដែលយើងត្រូវថ្វាយបង្គំ ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

តើនរណាមានសិទ្ធិថ្វាយបង្គំព្រះជាម្ចាស់?

ដើម្បីឆ្លើយនឹងសំណួរនេះ សូមយើងអានខ៦ទាំងអស់គ្នាម្តងទៀត បី ពីរ មួយ "គួរឱ្យជីវិតទាំងឡាយដែលមានដង្ហើមបានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ"។ ខនេះសង្កត់ន័យយ៉ាងធ្ងន់ទៅលើជីវិតទាំងឡាយដែលមាន"ដង្ហើម"។ ជីវិតទាំងឡាយនិយាយសំដៅឆ្ពោះទៅកាន់មនុស្សលោក។ ព្រះជាម្ចាស់បង្កើតមនុស្សលោកមកក្នុងវត្ថុបំណង អោយមនុស្សមានការប្រកបយ៉ាងជិតស្និទ្ធជាមួយនឹងព្រះអង្គ។ ការប្រកបយ៉ាងជិតស្និទ្ធ មានរួមទាំងការថ្វាយពាក្យសរសើរដល់ព្រះអង្គ និងកិរិយាប្រព្រឹត្តរស់នៅដោយបរិសុទ្ធ សម្រាប់ជាទីតម្កើងសិរីល្អទ្រង់។ តើអ្វីជាគោលដៅចម្បងបង្អស់នៃជីវិតមនុស្ស? គោលដៅចម្បងបង្អស់សម្រាប់ជីវិតមនុស្សគឺ ថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ព្រមទាំងរស់នៅយ៉ាងមានសុភមង្គលជាមួយព្រះអង្គអស់កល្បជានិច្ចតរៀងទៅ។

ព្រះជាម្ចាស់បង្កើតលោកសន្និវាសមក ដើម្បីថ្វាយសិរីល្អដល់ទ្រង់។ គម្ពីរយ៉ូបសម្តែងថា "...ផ្កាយព្រឹកបានច្រៀងជាមួយគ្នា ហើយអស់ទាំងកូនព្រះបានស្រែកអរសាទរ" (យ៉ូប៣៨:៧)។ លោកសន្និវាសនិងអ្វីៗទាំងអស់ដែលមាននៅលើលោកនេះបង្កើតមកសម្រាប់ថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់។ មិនតែប៉ុណ្ណោះ គម្ពីរទំនុកដំកើងជំពូក៩៦:៥ចែងទៀតថា "...អស់ទាំងព្រះរបស់សាសន៍ដទៃ សុទ្ធតែជារបស់ឥតប្រយោជន៍ តែព្រះយេហូវ៉ាវិញ ទ្រង់បានបង្កើតផ្ទៃមេឃ"។ ព្រះអង្គបង្កើតស្ថានសួគ៌

មក ដើម្បីធ្វើជាឧបករណ៍តន្ត្រីប្រគំថ្វាយបង្គំព្រះអង្គចាប់តាំងពីគ្រាអស់កល្បជានិច្ចកន្លងទៅ រហូតដល់គ្រាអស់កល្បជានិច្ចនៅអនាគត។ ព្រះជាម្ចាស់បង្កើតមនុស្សលោកមកសម្រាប់ថ្វាយបង្គំទ្រង់។ ប៉ុន្តែជាអកុសលណាស់ មនុស្សលោកបានធ្លាក់ពីសណ្ឋានដើមដើរច្រាសចាកផ្លូវរបស់ខ្លួនឆ្ងាយពីព្រះជាម្ចាស់បន្តិចម្តងៗរៀងរហូតមក។ សព្វថ្ងៃនេះមនុស្សលែងស្គាល់ព្រះជាម្ចាស់សោះតែម្តង។ មនុស្សភាគច្រើនមិនស្គាល់ព្រះជាម្ចាស់ដែលទ្រង់បង្កើតខ្លួនអោយរស់នៅលើផែនដីនេះ។ តាមពិតព្រះជាម្ចាស់បង្កើតមនុស្សលោកមក សម្រាប់អោយថ្វាយពាក្យសរសើរ និងថ្វាយសិរីល្អដល់ព្រះអង្គរៀងរាល់ដង្ហើមចេញចូល។ ប៉ុន្តែ យើងជាមនុស្សលោកដើរនៅក្នុងផ្លូវ ក្នុងវិស័យភ្លេងគេហៅថាខ្ទង់ឈ្លើយ។ ឧបករណ៍តន្ត្រីទាំងអស់ដែលព្រះជាម្ចាស់បង្កើតមក សុទ្ធតែរឹតត្រូវខ្ទង់គ្នាលើកលែងតែមនុស្សលោកប៉ុណ្ណោះ ដែលមានខ្ទង់ឈ្លើយ ភ្លេងជីវិតខុសសម្លេងដើមសម្រាប់ថ្វាយសិរីល្អដល់ព្រះជាម្ចាស់។

សេចក្តីពណ៌នាខាងលើ នាំអោយខ្ញុំនឹកឃើញពីការសិក្សាវិជ្ជាតន្ត្រី។ ខ្ញុំមិនព្វកែលេងឧបករណ៍តន្ត្រីប៉ុន្មានទេ។ ខ្ញុំយល់ល្មមត្រឹមអាចរឹតចាប៉ីអោយបានត្រូវនឹងសម្លេងមនុស្សច្រៀង។ ដើម្បីប្រគំភ្លេងយើងត្រូវរឹតសម្លេងអោយត្រូវខ្ទង់គ្នា ទើបប្រគំទៅវាពិរោះ។ ខ្ញុំសូមជូនឧទាហរណ៍ពីការប្រើឧបករណ៍ភ្លេងបួនប្រភេទមាន ខ្លុយ ទ្រ ស្គរនិងចាប៉ី។ ខ្លុយនិងទ្រលេងសម្រាប់អបឧបករណ៍ដទៃទៀត។ ស្គរលេងសម្រាប់ជីកនាំចង្វាក់ឧបករណ៍ឯទៀតអោយត្រូវពេលចូលបទ។ ចំណែកចាប៉ីលេងសម្រាប់អបសម្លេងអ្នកច្រៀង។ នៅក្នុងចំណោមឧបករណ៍ទាំងបួនប្រភេទនោះ ចាប៉ីជាឧបករណ៍ងាយ

ឈ្លើយខ្ពង់ ពីព្រោះសម្លេងមនុស្សមានចាបឈ្លើយខ្ពង់ មិនស៊ីជាមួយនឹងសម្លេងឧបករណ៍ដទៃទៀត ដែលត្រូវលេងថ្វាយសិរីល្អដល់ព្រះជាម្ចាស់។

ព្រះជាម្ចាស់បង្កើតលោកសន្និវាសមក ធ្វើជាឧបករណ៍តន្ត្រីសម្រាប់សរសើរតម្កើងព្រះអង្គ។ ក្នុងប្រវត្តិសាស្ត្រនៃមនុស្សលោក មានថ្ងៃមួយព្រះអម្ចាស់យេស៊ូវគ្រីស្ទយាងមកផែនដីនេះ ធ្វើជាអ្នកនាំមុខតន្ត្រីករប្រគំឧបករណ៍តន្ត្រីគ្រប់ប្រភេទ ប្រគំថ្វាយសិរីល្អដល់ព្រះជាម្ចាស់។ នៅពេលនោះព្រះអង្គបង្គាប់ដល់ពន្លឺថ្ងៃ អោយច្រៀងសម្លេងយ៉ាងពីរោះ។ ទ្រង់បង្គាប់ដល់ពួកលេងខ្លុយអោយចាប់ប្រគំ។ ពេលនោះខ្លុយបន្លឺសម្លេងយ៉ាងក្រអូន ថ្វាយបង្គំព្រះជាម្ចាស់។ នៅពេលខ្លុយបន្លឺសម្លេងឡើង សត្វស្លាបទាំងអម្បាលមាណច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់។ ព្រះអង្គបង្គាប់ដល់អ្នកកាន់ទ្រអោយប្រគំ។ នៅពេលទ្របន្លឺសម្លេងឡើង ពន្លឺទាំងអម្បាលមាណដែលមាននៅលើលោកនាំគ្នាជះពន្លឺយ៉ាងចាំងចែង។ នៅពេលនោះពពួកទេវតានាំគ្នាលើកសម្លេងថ្វាយបង្គំទ្រង់។ បន្ទាប់មកទៀត ទ្រង់បានបង្គាប់ដល់ពួកកាន់ស្គរអោយប្រគំ។ ពេលនោះផ្គរលាន់ទាំងតូចទាំងធំ ទាំងធ្ងន់ទាំងស្រាល បានបន្លឺសម្លេងលាន់ឮយ៉ាងខ្ទរខ្ទារ ថ្វាយបង្គំដល់ព្រះជាម្ចាស់ដែរ។ ព្រះអង្គក៏បង្គាប់ដល់ពួកកាន់ចាប៉ីអោយប្រគំឡើង។ នៅពេលពួកលេងចាប៉ីប្រគំឡើង សម្លេងចាប៉ីឈ្លើយខ្ពង់ទាំងអស់ឥតមានសល់មួយគ្រឿងទេ។ ដូច្នេះ តើព្រះអង្គត្រូវធ្វើដូចម្តេច? ព្រះអម្ចាស់យេស៊ូវគ្រីស្ទ មិនមែនគ្រាន់តែជាព្រះដែលបង្គាប់ដល់តន្ត្រីករ អោយប្រគំសរសើរតម្កើងព្រះអង្គតែម្យ៉ាងប៉ុណ្ណោះទេ ព្រះអង្គអាចប្រោសអំពើចាបពួកតន្ត្រីករអោយបានជា ព្រមទាំងជួសជុលឧបករណ៍ភ្លេង

ដែលខ្វះខាត អោយបានល្អប្រសើរឡើងវិញថែមទៀតផង។

ព្រះអម្ចាស់ទតឃើញថា មនុស្សលោកមានខ្ពង់ឈ្ងើយខុសពីភ្លេងដទៃៗទៀត ដែលព្រះជាម្ចាស់បានបង្កើតមកសម្រាប់សរសើរតម្កើងដល់ព្រះអង្គ។ ដូច្នេះ ព្រះអង្គ បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទអោយមកសុគតជំនួស មនុស្សមានបាប ដើម្បីអោយគេអាចបកត្រឡប់ទៅថ្វាយបង្គំដល់ព្រះជាម្ចាស់វិញ។ ព្រះ អម្ចាស់យេស៊ូវគ្រីស្ទត្រូវគេយកទ្រង់ទៅបញ្ចុះក្នុងផ្នូរ។ បីថ្ងៃក្រោយមក ទ្រង់រស់ឡើង វិញ ដើម្បីផ្តល់សេចក្តីសុចរិតដល់មនុស្សមានបាបណាដែលជឿដល់ទ្រង់។ ដូច្នេះ អ្នក ដែលបានទទួលសេចក្តីប្រោសលោះតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ អាចនិយាយបាន ថា: "ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្តីសប្បុរសនៃទ្រង់ស្ថិត ស្ថេរនៅជានិច្ច..." (ទំនុកដំកើង១០៧:១-២)។ អ្នកដែលព្រះអម្ចាស់ផ្តល់ការប្រោស លោះ គួរតែជាអ្នកដែលចេះលើកសម្លេងឡើង អោយត្រូវនឹងសម្លេងឧបករណ៍ដទៃ ទៀតនៅស្ថានសួគ៌ ថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់។ អ្នកដែលទទួលការប្រោស លោះ ទើបមានសិទ្ធិច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់។ គេត្រូវថ្វាយពាក្យសរសើរ ដល់ព្រះជាម្ចាស់ដោយបបូរមាត់ផង ដោយជីវិតរស់នៅយ៉ាងបរិសុទ្ធផង។

ហេតុអ្វីបានជាត្រូវថ្វាយបង្គំដល់ព្រះជាម្ចាស់?

មនុស្សតិចណាស់ដឹងថាខ្លួនត្រូវថ្វាយបង្គំព្រះជាម្ចាស់។ នៅក្នុងចំណោមអ្នកមិនទាន់បានទទួលសេចក្តីប្រោសលោះនៅឡើយ គេមិនដឹងថា ហេតុអ្វីបានជាគេចាំបាច់ត្រូវថ្វាយបង្គំដល់ព្រះជាម្ចាស់ទេ។ ដំណើរនោះមកពីហេតុគេមិនដឹង។ ប៉ុន្តែ ចំពោះជនដែលមើលទៅហាក់ដូចជាបានទទួលការប្រោសលោះរួចហើយ នៅមានមនុស្សខ្លះមិនទាន់ដឹងថា ហេតុអ្វីបានជាខ្លួនត្រូវថ្វាយបង្គំដល់ព្រះជាម្ចាស់ផង។ ការថ្វាយបង្គំដល់ព្រះជាម្ចាស់ ត្រូវធ្វើដោយមានទំនាក់ទំនងល្អរវាងចិត្តរបស់បុគ្គលម្នាក់ជាមួយនឹងព្រះជាម្ចាស់ផ្ទាល់។ លោកខ្វាយ-សូតីម ជាបិតាជំនឿមួយរូបបានមានប្រសាសន៍ថា: "ពពួកទេវតាលើកតម្កើងដល់ព្រះជាម្ចាស់ ពពួកមនុស្សលោកបង្គាប់បង្គោនព្រះនាមព្រះអង្គ ពពួកទេវតាបិទមុខខ្លាចភាពបរិសុទ្ធរបស់ព្រះ ពពួកមនុស្សលោកមានកិរិយាព្រហើនបង្ហូតសិរីល្អរបស់ខ្លួនជាមួយនឹងសិរីល្អរបស់ព្រះជាម្ចាស់"។ លោកអ្នកបងប្អូនអើយ មនុស្សលោកសព្វថ្ងៃបង្ហូតសិរីល្អរបស់ខ្លួន ជាមួយនឹងសិរីល្អរបស់ព្រះជាម្ចាស់។ គ្រីស្ទបរិស័ទខ្លះ ចូលទៅថ្វាយបង្គំព្រះជាម្ចាស់អួតពីអំពើល្អរបស់ខ្លួន។ កាលណាបុគ្គលម្នាក់មានកិរិយាបង្ហូតពីអំពើល្អរបស់ខ្លួននៅចំពោះព្រះជាម្ចាស់ហើយ បុគ្គលនោះមិនបានថ្វាយបង្គំដល់ព្រះជាម្ចាស់ទេ។ ការថ្វាយបង្គំដល់ព្រះជាម្ចាស់ ជាកិរិយាប្តូរវិញ្ញាណចូលចំពោះវត្តមានរបស់ព្រះជាម្ចាស់។

នៅក្នុងការថ្វាយបង្គំ មានកិរិយាបីយ៉ាងដែលវន្ទាករគ្រប់រូបត្រូវមានទំនាក់ទំនងផ្ទាល់ជាមួយព្រះជាម្ចាស់។ កិរិយាទាំងបីនោះគឺ មួយកិរិយាក្រាបវន្ទា ពីរកិរិយាលើកតម្កើង និងបី កិរិយាគោរពយ៉ាងខ្ពង់ខ្ពស់។

ការថ្វាយបង្គំ មានរួមទាំងការថ្វាយក្រាបវន្ទានៅចំពោះព្រះជាម្ចាស់។ ការនេះ ខ្ញុំមិនមែននិយាយគ្រាន់តែលើកដៃសំពះក្រាបក្បាលដល់ដីតែប៉ុណ្ណោះទេ។ អ្នកខ្លះក្រាបក្បាលដល់ដី លើកដៃសំពះ តែចិត្តវឹងជាងដែកថែប។ ការថ្វាយក្រាបវន្ទានៅចំពោះព្រះជាម្ចាស់ មិនទាក់ទងនឹងរូបភាពនៃរូបកាយទេ។ យើងត្រូវថ្វាយបង្គំព្រះជាម្ចាស់ដោយក្រាបវន្ទាទាំងចិត្ត ទាំងព្រលឹងរបស់យើងនៅចំពោះទ្រង់។

នៅពេលដែលយើងមានការតានតឹងក្នុងជីវិត យើងត្រូវស្វែងរកទីកន្លែងស្ងាត់ដើម្បីប្រកបជាមួយនឹងព្រះជាម្ចាស់ដោយផ្ទាល់ខ្លួន។ ការចំណាយពេលផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់ហៅថា ការធ្វើសន្តិពេលា។ ខ្ញុំសូមសួរដល់លោកអ្នកបងប្អូនថា តើថ្ងៃនេះលោកអ្នកបានចូលទៅក្រាបវន្ទានៅចំពោះព្រះជាម្ចាស់ផ្ទាល់ខ្លួនដែរឬទេ?

ការថ្វាយមួយទៀតក្នុងការថ្វាយបង្គំ គឺការលើកតម្កើងព្រះនាមព្រះជាម្ចាស់ដោយស្រឡាញ់ទ្រង់។ គម្ពីរទំនុកដំកើងជំពូក៩៦:៩ចែងថា "ចូរថ្វាយបង្គំដល់ព្រះយេហូវ៉ាដោយពាក់គ្រឿងជ័បរិសុទ្ធ ឱផែនដីទាំងមូលអើយ ចូរញាប់ញ័រនៅចំពោះទ្រង់ចុះ"។ ការថ្វាយបង្គំដល់ព្រះជាម្ចាស់ ជាការខ្ជាក់នូវសេចក្តីស្រឡាញ់របស់យើងនៅចំពោះទ្រង់។ ការថ្វាយបង្គំដល់ព្រះជាម្ចាស់ ត្រូវធ្វើឡើងដោយមានចិត្តស្រឡាញ់។ ស្តេចដាវីឌបានថ្វាយបង្គំដល់ព្រះជាម្ចាស់ ដោយស្រឡាញ់ដល់ទ្រង់។ គម្ពីរ២សាំយូអែល ៦:១៥-១៦ ចែងថា: "ដូច្នេះ ដាវីឌនឹងជនទូវង្សនៃសាសន៍អ៊ីស្រាអែលទាំងអស់ បាននាំហឺបនៃព្រះយេហូវ៉ាឡើងមកដោយសំឡេងហ៊ោឡើង នឹងសូរផ្ទុំត្រែផងក្នុងវេលាដែលហឺបនៃព្រះយេហូវ៉ាកំពុងតែចូលមកក្នុងក្រុងដាវីឌ នោះមីកាលជាបុត្រីសូល ក៏ទតតាម

បង្អួចទៅឃើញស្តេចដាវីឌ កំពុងតែហក់លោតកញ្ឆេងនៅចំពោះព្រះយេហូវ៉ា នាងក៏មានព្រះទ័យប្រមាថមើលងាយដល់ទ្រង់"។ ស្តេចដាវីឌស្រឡាញ់ដល់ព្រះជាម្ចាស់ថាន ជាលោកថ្វាយបង្គំទ្រង់ដោយលោតកញ្ឆេងយ៉ាងអស់ពីចិត្ត។ កិរិយាថ្វាយបង្គំដល់ព្រះជាម្ចាស់ ត្រូវប្រសូតចេញពីសេចក្តីស្រឡាញ់។ ការថ្វាយបង្គំដល់ព្រះជាម្ចាស់ដោយគ្មានសេចក្តីស្រឡាញ់ ប្រៀបឧបមាដូចជាអណ្តាតភ្លើងគ្មានកំដៅ ដូចជាឥន្ទធនូគ្មានពណ៌ ដូចទឹកអប់គ្មានក្លិន។ លោកអ្នកបងប្អូនអើយ យើងចាំបាច់ត្រូវមានសេចក្តីស្រឡាញ់យ៉ាងមោះមុតចំពោះព្រះជាម្ចាស់ ទើបយើងថ្វាយបង្គំដល់ព្រះអង្គ ដោយកិរិយាលើកតម្កើងព្រះនាមព្រះអង្គបាន។

តើសព្វថ្ងៃ មនុស្សលោកថ្វាយបង្គំដល់ព្រះជាម្ចាស់មានទឹកចិត្តបែបណា? មានយុវជនមួយរូបសរសេរសំបុត្រទៅកាន់សង្ឃរបស់ខ្លួនថា: "អូនអើយ! បងស្រឡាញ់អូនយ៉ាងខ្លួលខ្ចាញ់ក្នុងបេះដូង។ ទោះបីភ្នំខ្ពស់យ៉ាងណាក៏បងសុខចិត្តឡើងទៅ ទោះបីមហាសាគរជ្រៅយ៉ាងណា ក៏បងសុខចិត្តហែលឆ្លង ទោះបីភ្នំភ្លើងកំពុងផ្ទុះយ៉ាងណាក៏ដោយ ក៏បងសុខចិត្តទៅជូបអូនតាមពេលកំណត់"។ នៅចុងបញ្ចប់នៃសំបុត្រ យុវជននោះសរសេរបន្ថែមថា: "យប់នេះ ពេលឮសម្លេងបង សូមចាប់ឆ្កែញីអត់ធ្មេញចងអោយហើយផង!" មនុស្សលោកសព្វថ្ងៃថ្វាយបង្គំដល់ព្រះជាម្ចាស់ មានលក្ខណៈមិនខុសពីទឹកចិត្តរបស់យុវជនមួយរូបនេះ ស្រឡាញ់ដល់សង្ឃរបស់ខ្លួនទេ។ ការរវល់តែបន្តិចបន្តួចអាចទាញនាំយើង អោយដាច់ឆ្ងាយចេញពីព្រះជាម្ចាស់យ៉ាងងាយ។ យើងត្រូវស្រឡាញ់ដល់ព្រះជាម្ចាស់ ទើបយើងលើកតម្កើង ព្រះអង្គចេញជាកិរិយាថ្វាយបង្គំ

ដល់ទ្រង់។

កិរិយាទីបីដែលរាប់ថាជាការថ្វាយបង្គំព្រះអង្គ ទាក់ទងនឹងការគោរពយ៉ាងខ្ពង់ខ្ពស់ដល់ភាវៈ ដែលព្រះជាម្ចាស់រាប់ថាមានតម្លៃខ្ពស់។ ចំណុចនេះ ខ្ញុំមិនមែននិយាយពីការអោយតម្លៃខ្ពស់ដល់ព្រះជាម្ចាស់ទេ។ ទោះបីយើងថ្វាយបង្គំ ឬមិនថ្វាយបង្គំទ្រង់ ព្រះអង្គមានតម្លៃខ្ពស់ឥតមានអ្វីយកមកប្រៀបផ្ទឹមជាមួយព្រះអង្គបានជាដាច់ខាត។ បើយើងពិតជាថ្វាយបង្គំដល់ព្រះជាម្ចាស់មែន យើងមានចិត្តគោរពយ៉ាងខ្ពង់ខ្ពស់ដល់មនុស្សគ្រប់រូប។ ព្រះជាម្ចាស់អោយតម្លៃខ្ពស់ដល់មនុស្សគ្រប់រូប។ ព្រះអង្គប្រទានព្រះរាជបុត្រាព្រះអង្គតែមួយគត់ ដើម្បីសុគតជំនួសមនុស្សលោក ព្រោះទ្រង់រាប់មនុស្សថាមានតម្លៃខ្ពស់ណាស់។ បើយើងពិតជាថ្វាយបង្គំព្រះអង្គមែន យើងពិតជាអោយតម្លៃខ្ពស់ដល់មនុស្សគ្រប់រូប ទោះអ្នកនោះជាសត្រូវរបស់យើង ក៏យើងត្រូវអោយតម្លៃគេខ្ពស់ ដូចព្រះជាម្ចាស់រាប់គេថាខ្ពស់ដែរ។

ចលនាមនុស្សធម៌ បានគ្រប់គ្រងគំនិតមនុស្សអស់រយៈពេលជិតកន្លះសតវត្សរ៍កន្លងមកហើយ។ ទីបំផុតចលនាមនុស្សធម៌ នាំអោយមនុស្សខ្លះបែរជាសម្លាប់មនុស្សគ្នាឯងដូចសត្វធាតុទេវិញ។ ករណីលោកហ៊ីត្លែសម្លាប់មនុស្សអស់រាប់លាននាក់ ជាលទ្ធផលនៃចលនាមនុស្សធម៌នេះ។ ករណីខ្មែរក្រហមសម្លាប់មនុស្សអស់រាប់លាននាក់ ក៏ជាលទ្ធផលនៃចលនាមនុស្សធម៌នេះដូចគ្នា។ លោកអ្នកបងប្អូនអើយ ចលនាមនុស្សធម៌នាំអោយមនុស្សលោកបែរខ្នងដាក់ព្រះជាម្ចាស់។ កាលណាមនុស្សលោកបែរខ្នងដាក់ព្រះជាម្ចាស់មនុស្សលោកចាំបាច់ត្រូវលើកមនុស្សណាម្នាក់ដើម្បីថ្វាយបង្គំ។ កាលណាលែង

ថ្វាយបង្គំព្រះជាម្ចាស់ មនុស្សលោកលែងអោយតម្លៃមនុស្សលោកដូចគ្នាខ្ពស់ទៀតហើយ។ ដូច្នេះ ការអោយតម្លៃខ្ពស់ដល់មនុស្សលោក ការគោរពសិទ្ធិមនុស្សពិតប្រាកដប្រសូតចេញមកពីកិរិយាថ្វាយបង្គំដល់ព្រះជាម្ចាស់។ ការថ្វាយបង្គំពិតប្រាកដដល់ព្រះជាម្ចាស់ ពេលខ្ញុំអោយចិត្តអ្នកថ្វាយបង្គំចេះគោរពមនុស្សលោកដូចគ្នាយ៉ាងខ្ពង់ខ្ពស់។

នៅសតវត្សរ៍ទីដប់ប្រាំពីរ មានអ្នកប្រាជ្ញម្នាក់នាមម៉ូរិតីស។ លោកជាអ្នកប្រាជ្ញមួយរូបធ្វើដំណើរមកដល់ភូមិឡាំចាឌី។ នៅពេលលោកធ្វើដំណើរមកដល់ទីនោះ លោកមានជម្ងឺធ្ងន់ រហូតដល់ដួលសន្លប់នៅតាមផ្លូវ។ មានគេជីកលោកតាមរនេះសេះមកដាក់នៅមន្ទីពេទ្យ។ ក្រែងលោមានគេព្យាបាលដល់រូបលោក។ គាប់ជួនពេលនោះគ្រូពេទ្យមួយក្រុមត្រូវការមនុស្សម្នាក់ដើម្បីវះកាត់ពិសោធន៍មើល។ គ្រូពេទ្យវះកាត់ម្នាក់បាននិយាយជាភាសាឡាតាំងថា: យើង "ត្រូវយកមនុស្សកំទេចកំទីមួយរូបនេះ មកវះដកពិសោធន៍មើល!" លោកម៉ូរិតីសយល់គេនិយាយជាភាសាឡាតាំង ទើបលោកតបទៅគេវិញថា: "មិនត្រូវរាប់មនុស្សដែលព្រះយេស៊ូវសុគតជំនួសរួចហើយ ថាជាមនុស្សគ្មានតម្លៃបែបនេះទេ!" លោកអ្នកបងប្អូនអើយ ការថ្វាយបង្គំដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទញុំាងយើងអោយចេះតម្លៃខ្ពស់ដល់មនុស្សជាតិ ទោះអ្នកនោះមានឋានៈ វណ្ណៈ ពណ៌សម្បុរបែបណាក៏ដោយ។

មនុស្សលោកជាមាបនភាវៈមួយប្រភេទ ដែលព្រះជាម្ចាស់បង្កើតមកមានខ្ពង់សម្លេងឈ្លើយខុសពីសម្លេងឧបករណ៍តន្ត្រីផ្សេងៗទៀត ដែលត្រូវប្រគំសរសើរតម្កើងព្រះអង្គ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ព្រះអម្ចាស់យេស៊ូវគ្រីស្ទបានទិញមនុស្ស

លោកពីអំពើចាបរបស់ខ្លួន។ ជនណាដែលជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ អាចមានខ្ពង់សម្លេងត្រូវនឹងសម្លេងឧបករណ៍តន្ត្រីផ្សេងទៀត ដែលព្រះជាម្ចាស់បង្កើតមកក្នុងលោកសន្និវាសនេះ ដើម្បីថ្វាយពាក្យសរសើរដល់ព្រះអង្គ។ គម្ពីរទំនុកដំកើងជំពូក១៥០ ផ្តើមឡើងដោយព្រះរាជបុត្រារបស់ទ្រង់ គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទប្រោសលោះមនុស្សលោក អោយមានសណ្ឋានដូចដើមឡើងវិញ។ បន្ទាប់ពីបានទទួលការស្រោចស្រង់អោយមានសណ្ឋានដូចដើមឡើងវិញហើយ អ្នកដែលព្រះជាម្ចាស់ប្រោសលោះអាចសរសើរតម្កើងដល់ព្រះជាម្ចាស់បាន។ ឥឡូវនេះ ព្រះអម្ចាស់យេស៊ូវគ្រីស្ទបង្គាប់ដល់អ្នកលេងខ្លុយ អោយគេលេងបទសរសើរ ខ្លុយក៏លេងឡើងជាបទចម្រៀងថា: "ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះនៅក្នុងទីបរិសុទ្ធទ្រង់ ចូរសរសើរដល់ទ្រង់នៅចន្លោះអាកាសជាទីសម្តែងព្រះចេស្តាទ្រង់"។

បន្ទាប់មកព្រះអង្គបង្គាប់ដល់ទ្រអោយលេងបទសរសើរតម្កើងព្រះអង្គ ទ្រក៏លេងសម្លេងជាបទសរសើរថា: "ចូរសរសើរដល់ទ្រង់ ដោយព្រោះឥទ្ធិឫទ្ធិរបស់ទ្រង់ ចូរសរសើរដល់ទ្រង់អោយសមនឹងសណ្ឋានដ៏ធំប្រសើររបស់ទ្រង់"។

ព្រះអង្គបង្គាប់ដល់ពួកលេងស្គរ អោយលេងបទសរសើរ។ ស្គរក៏បបួលឧបករណ៍តន្ត្រីឯទៀតអោយរួមសរសើរព្រះអង្គថា: "ចូរសរសើរទ្រង់ដោយស្គរត្រែ ចូរសរសើរទ្រង់ដោយដេញពិណ ចូរសរសើរទ្រង់ដោយចាប់ស៊ុង"។ ស្គរលេងជាចង្វាក់ផ្តល់អោយត្រែ ពិណនិងស៊ុងត្រូវលេងតាមទំនងចង្វាក់រៀងៗខ្លួន។

បន្ទាប់មក ព្រះអង្គបង្គាប់ដល់ចាប៉ីអោយច្រៀងសរសើរតម្កើងព្រះអង្គ

ដោយមានសម្លេងមនុស្សដែលទ្រង់ព្រោសលោះច្រៀងថា: "ចូរសរសើរដល់ទ្រង់ដោយវាយក្រាប់ ហើយលោតកញ្ឆេង ចូរសរសើរទ្រង់ដោយប្រដាប់មានខ្សែ ហើយនឹងខ្ពុយ ចូរសរសើរដល់ទ្រង់ដោយវាយឈឹងឱ្យឮរងំ ចូរសរសើរទ្រង់ដោយវាយឈឹងឮស្ងរំពង"។ បន្ទាប់ពីនោះមក ឧបករណ៍តន្ត្រីគ្រប់ប្រភេទដែលព្រះជាម្ចាស់បានបង្កើតមកក្នុងលោកសន្និវាស ក៏លេងសរសើរព្រមគ្នាតម្កើងព្រះអង្គ។ ឯមនុស្សលោកដែលព្រះជាម្ចាស់ព្រោសលោះ ក៏ច្រៀងសរសើរតម្កើងដល់ព្រះជាម្ចាស់ បន្តរដោយឧបករណ៍តន្ត្រីទាំងឡាយ ដែលព្រះជាម្ចាស់បង្កើតនៅលើលោកសន្និវាសយើងនេះ។ ចម្រៀងមួយបទ ដែលព្រះអម្ចាស់យេស៊ូវគ្រីស្ទដឹកនាំ មានឧបករណ៍តន្ត្រីគ្រប់ប្រភេទឥតគណនា ព្រមទាំងមនុស្សលោក ដែលព្រះជាម្ចាស់ព្រោសលោះបានច្រៀងបន្តរជាមួយគ្នាលាន់ឮអឺង កងជាសកលក្នុងលោកសន្និវាសយើង។ បទសរសើរជាលក្ខណៈសកលមានខ្លឹមសារដូចខាងក្រោមនេះ :

"ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះ នៅក្នុងទីបរិសុទ្ធរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ នៅចន្លោះអាកាសជាទីសំដែងព្រះចេស្តាទ្រង់ ចូរសរសើរដល់ទ្រង់ ដោយព្រោះឥទ្ធិឫទ្ធិរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ ឱ្យសមនឹងសណ្ឋានដ៏ធំប្រសើរបស់ទ្រង់ ចូរសរសើរទ្រង់ដោយស្នូរត្រែ ចូរសរសើរដល់ទ្រង់ដោយដេញពិណនឹងចាប់ស៊ុង ចូរសរសើរដល់ទ្រង់ដោយវាយក្រាប់ ហើយលោតកញ្ឆេង ចូរសរសើរទ្រង់ដោយប្រដាប់មានខ្សែ ហើយនឹងខ្ពុយ ចូរសរសើរដល់ទ្រង់ដោយវាយឈឹងឱ្យឮរងំ ចូរសរសើរទ្រង់ដោយវាយឈឹងឮស្ងរំពង គួរឱ្យជីវិតទាំងឡាយដែលមានដង្ហើម បាន

សរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ"។

គម្ពីរទំនុកដំកើងជំពូក១៥០ ជាការប្រគំឧបករណ៍តន្ត្រីសព្វបែបយ៉ាងក្នុងលោកសន្និវាស អមជាមួយនឹងសម្លេងមនុស្សលោកដែលព្រះជាម្ចាស់ទ្រង់ជ្រោសលោះតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ បទចម្រៀងនេះ ត្រូវប្រគំសរសើរតម្កើងព្រះអង្គនៅគ្រាអនាគត។ ទំរាំដល់ពេលនោះ ចូរយើងនាំគ្នាថ្វាយបង្គំព្រះអង្គដោយចិត្ត និងគំនិតក្រាបវន្ទានៅចំពោះព្រះអង្គ លើកតម្កើងព្រះនាមទ្រង់ ព្រមទាំងអោយតម្លៃខ្ពស់ដល់មនុស្សលោក ដែលព្រះជាម្ចាស់បង្កើតគេមកអោយរស់នៅលើលោកសន្និវាសរបស់ទ្រង់នេះផងចុះ។

យើងធ្វើការបញ្ចប់ការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះជាបរិបូរ។ សូមព្រះជាម្ចាស់ទទួលនូវការថ្វាយបង្គំ ការសរសើរតម្កើងពីយើងខ្ញុំទាំងអស់គ្នា។ យើងខ្ញុំសូមថ្លែងអរគុណដល់ព្រះជាម្ចាស់ ដ្បិតទ្រង់ប្រទានឱកាសអោយយើងបានរៀនសូត្រពីព្រះជាម្ចាស់។ សូមព្រះជាម្ចាស់បានប្រកបដោយព្រះពរដ៏អស់កល្បជានិច្ច។ អាម៉ែន និងអាម៉ែន!